**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
ចូល
លេខ...6199...
ថ្ងៃទី31..10..18 ម៉ោង3h25
បញ្ជូន...

**សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ**
**ក្រុមលទ្ធកម្ម**
លេខ ៖ ...០២៩...... សជសក/កល

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការជួសជុលកែលម្អសួនច្បារ ច្រាំងទន្លេ ជួសជុលអគារ ជួសជុលកែលម្អផ្លូវ និងជួសជុលបណ្តាញភ្លើងក្នុងសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ ឃុំស្មោងខាងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង ថវិកាកម្មវិធីឆ្នាំ ២០១៨ ជំពូក ៦១ ផ្នែកឧត្តមសិក្សា

សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជណាចក្រកម្ពុជា ឱ្យបានជ្រាបថា សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការស្តីពី**ការជួសជុលកែលម្អសួនច្បារ ច្រាំងទន្លេ ជួសជុលអគារ ជួសជុលកែលម្អផ្លូវ និងជួសជុលបណ្តាញភ្លើង** ក្នុងសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ។

សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ បានរៀបចំឯកសារ សម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃ មានដាក់លក់នៅក្រុមលទ្ធកម្ម សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ ដែលមានអាសយដ្ឋាន ភូមិថ្នល់កែង ឃុំស្មោងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង ចាប់ពីថ្ងៃទី១២ ខែ តុលា ឆ្នាំ ២០១៨ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០៩៥ ៧៧ ៦៦ ៦៨, ០១៦ ៩៩ ៦១ ៧៧) ។

ឯកសារដេញថ្លៃ ដែលបានបំពេញរួច ត្រូវប្រគល់ជូនក្រុមលទ្ធកម្មយ៉ាងយូរបំផុត ត្រឹមថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ **២០១៨ វេលាម៉ោង ១០:០០ ព្រឹក** ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅក្រុមលទ្ធកម្ម តាមអាសយដ្ឋានខាងលើ **វេលាម៉ោង ១០:០០ ព្រឹក ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៨** ។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬ មានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្ម ដើម្បីទទួលឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ ព្រហស្បតិ៍ ខែ អស្សុជ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២
កំចាយមារ, ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៨
**សាកលវិទ្យាធិការ**
**និងជាប្រធានក្រុមលទ្ធកម្ម**

**សិត ខន**

ចម្លងជូន
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ-កាលប្បវត្តិ

01.11.18